00723675

-1-

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 29 / 07 / 2011
ម៉ោង (Time/Heure) : 13:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ~~០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស (អបជ)០១~~ 003/29-07-2011 - ECCC/PTC 01

ភាគីដាក់ឯកសារ: Nisha Valabhji មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ [កោសលុប]

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សម្ងាត់ / Confidential / Confidentiel

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: សាធារណៈ / Public (កោសលុប)

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅចំពោះអង្គបុរេជំនុំជម្រះ និងសុំឲ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធិភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣**

---

**ដាក់ដោយ៖**

**មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី**

Nisha Valabhji

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

SAM Sokong
Lyma Thuy NGUYEN

CHOUNG Chou-Ngy

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

## I. សេចក្ដីផ្ដើម

១. ការបន្តដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ("អបជ") នៅក្នុងសំណុំរឿង ០០៣ ដោយគ្មានការចូលរួមប្រកបដោយប្រសិទ្ធិភាពពីមេធាវីការពារក្ដី នឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនសង្ស័យដែលមានចែងនៅក្នុងវិធាន២១(១) នៃវិធានផ្ទៃក្នុងរបស់អវតក ("វិធានផ្ទៃក្នុង")។

២. ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ មានសិទ្ធិទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពក្រោមវិធាន ២១(១) នៃវិធានផ្ទៃក្នុង ប៉ុន្តែបើតាមអង្គភាពគាំពារការការពារក្ដីបានដឹង និងថ្វីបើមានការខិតខំប្រែងប្រែងទាំងអស់របស់ខ្លួនមកដល់ពេលនេះ ជនសង្ស័យនៅតែពុំទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពនៅឡើយទេ ។

៣. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី ("OiC") សូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះផ្អាកដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះដើម្បីអនុញ្ញាតឱ្យអង្គភាពនេះចាត់វាល់វិធានការចាំបាច់ទាំងអស់ដើម្បីផ្ដល់ការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពដល់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ សម្រាប់គោលបំណងនៃដំណើរការនីតិវិធីទាំងនេះ និងបញ្ហាដទៃទៀតដែលអង្គជំនុំជម្រះយល់ឃើញថាស័ក្តិសម។

៤. បន្ថែមពីលើនេះទៀត មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដីសូមស្នើដោយគោរពដល់អង្គបុរេជំនុំជម្រះចេញដីកាបង្គាប់ឱ្យការិយាល័យរដ្ឋបាល ("OA") ធ្វើតាមសំណើរបស់អង្គភាពគាំពារការការពារក្ដីដោយផ្ដល់ឱ្យអង្គភាពនេះនូវជំនួយផ្នែកពស្ដុភារ ហិរញ្ញវត្ថុ និងជំនួយខាងរដ្ឋបាលដែលចាំបាច់សម្រាប់ទាក់ទងជនសង្ស័យ និងផ្ដល់ឱ្យពួកគេនូវបញ្ជីឈ្មោះមេធាវី អនុលោមតាមវិធាន ១២ (២) (ង) នៃវិធានផ្ទៃក្នុង ។

៥. នៅដំណាក់កាលអន្តរកាលនេះ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី សូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះចេញដីកាមួយដល់អនុប្រធានការិយាល័យរដ្ឋបាល ("DDOA") ដើម្បីបង្គាប់ឱ្យគាត់ធ្វើតាមសំណើរបស់អង្គភាពគាំពារការការពារក្ដីដែលបានស្នើសុំឱ្យបន្តកិច្ចសន្យាការងារដល់ [redacted] មេធាវីដែលចាត់តាំងដោយអង្គភាពគាំពារការការពារក្ដីដើម្បីការពារផលប្រយោជន៍របស់ជនសង្ស័យរហូតដល់ពួកគេត្រូវបានចាត់តាំងមេធាវីរៀងៗខ្លួនតាមការជ្រើសរើសដោយខ្លួនឯង ។

## II. ការសង្ខេបអង្គហេតុពាក់ព័ន្ធ

00723677



## ២.១ ដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៣ ប៉ះពាល់ដល់ផលប្រយោជន៍របស់ជនសង្ស័យ

៦. សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ បានចេញសេចក្តីប្រកាសព័ត៌មានបញ្ជាក់ពីការដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរទៅសហចៅក្រមស៊ើបអង្កេត[1]។

៧. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញ "ការជូនដំណឹងពីការបញ្ចប់ការស៊ើបសួរ"អនុលោមតាមវិធាន៦៦(១)នៃវិធានផ្ទៃក្នុង[2]។ ចាប់តាំងពីការបើកកិច្ចស៊ើបសួរនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ រហូតដល់ចេញការជូនដំណឹងតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង "ការជូនដំណឹង" ពីការស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ ត្រូវបានធ្វើឡើងដោយគ្មានការចូលរួមពីមេធាវីការពារក្តី ។

៨. នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានចេញសេចក្តីប្រកាសព័ត៌មានដែលបានបង្ហាញព័ត៌មានជាក់លាក់មួយចំនួនចេញពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរទៅសាធារណជន រួមទាំងឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានស៊ើបអង្កេត និងដាក់បញ្ចូលនូវអនុសាសន៍នានារបស់គាត់ទាក់ទងនឹងការស៊ើបអង្កេតបន្ថែម ហើយព្រមទាំងបានជម្រុញឱ្យជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣[3]ទៀតផង ។

៩. នៅថ្ងៃទី១០ ខែ ឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំពន្យាពេលវេលាកំណត់សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើចំនួនបី (៣) សុំបំពេញកិច្ចស៊ើបសួរបន្ថែមនៅក្នុងសំណុំរឿង ០០៣[4] ។

---

[1] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី, ការិយាល័យសហព្រះរាជអាជ្ញានៃ អវតក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ ។

[2] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "ការជូនដំណឹងពីការបញ្ចប់ការស៊ើបសួរ", សហចៅក្រមស៊ើបសួរ, ឯកសារ D13 ERN: 00681127, ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ។

[3] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ។

[4] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលវេលាកំណត់ ដើម្បីដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣" ឯកសារ D15 ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ ។ ០០៣/០០៧-០៩-២០០៩-អវតក-កសចស "សំណើលើកទីមួយនៃសំណុំរឿង ០០៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យ

១០. ជាការឆ្លើយតបនឹងសេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិចុះថ្ងៃទី ៩ ខែឧសភា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ បានចេញ "សេចក្តីសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ("ដីកាសម្រេច")[5] ។

១១. នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[6] ។

១២. នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះចេញ "សេចក្តីសម្រេចព្យួរអនុវត្តដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣"[7] ។

១៣. នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចលើសំណើសុំពន្យារពេលវេលាកំណត់ និងសំណើសុំបំពេញកិច្ចស៊ើបអង្កេតដោយសហព្រះរាជអាជ្ញាអន្តរជាតិ

---

បំពេញកិច្ចស៊ើបសួរដើម្បីទទួលយកឯកសារបន្ថែម និងការកត់សម្គាល់ពីស្ថានភាពនៃការស៊ើបសួរ" ឯកសារ D17, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ។ ០០៣/០០៧-០៩-២០០៩-អវតក-កសចស "សំណើលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទងនឹង "[កោសលុប] ទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ" ឯកសារ D18, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ។ ០០៣/០០៧-០៩-២០០៩-អវតក-កសចស "សំណើលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹង "[កោសលុប] ទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ" ឯកសារ D19, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ (លើកមកសំអាងនៅក្នុងសំណុំរឿង ០០៣/០០៧-០៩-២០០៩-អវតក-កសចស ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំពន្យារពេលវេលាកំណត់ និងសំណើសុំបំពេញកិច្ចស៊ើបសួរដោយសហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣" ឯកសារ D20/3 ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ នៅកថាខណ្ឌទី ១ អក្សរក្នុងលេខយោងលេខ ២,៣ ។

[5] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ឯកសារ D14 (ERN 00693898) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ។

[6] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ឯកសារ D14/1/1 (ERN 00700029) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ។

[7] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "សេចក្តីសម្រេចព្យួរអនុវត្តដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" អង្គបុរេជំនុំជម្រះ D14/1/2 (ERN 00704894) ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ ។

ទាក់ទងនឹងសំណុំរឿង ០០៣"[8] ។

១៤. នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១[9] ។

១៥. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានដាក់សារណានៅចំពោះមុខអង្គបុរេជំនុំជម្រះដែរ ។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី [redacted] បានដាក់ "សំណើសុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីភាពអាចទទួលយកបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted] ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឱ្យចូលមើលសំណុំរឿង ០០៣ និង ០០៤"[10] ។

១៦. នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី [redacted] បានដាក់ "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីភាពទទួលយកបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted]"[11] ។

---

[8] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "ដីកាសម្រេចលើសំណើសុំពន្យារពេលវេលាកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" សហចៅក្រមស៊ើបអង្កេត D20/3 ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ២០១១ ។

[9] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំពន្យារពេលវេលាកំណត់ និងសំណើសុំបំពេញកិច្ចស៊ើបសួរដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ឯកសារ D20/4/1 (ERN 00712851) ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១- ឯកសារនេះត្រូវបានចំណាត់ថ្នាក់ជាសម្ងាត់ ប៉ុន្តែត្រូវបានជូនដំណឹងមកអង្គភាព DSS ដោយមន្ត្រីសំណុំរឿង អវតក ។

[10] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "សំណើសុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្ដីពីភាពអាចទទួលយកបានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted] ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឱ្យចូលមើលសំណុំរឿង ០០៣ និង ០០៤" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ ។ ឯកសារនេះត្រូវបានចំណាត់ថ្នាក់ជា "សម្ងាត់" ប៉ុន្តែត្រូវបានយោងជា ០០៣/០០៧-០៩-២០០៩-អវតក-កសចស(អជបប០២) "ការជូនដំណឹងដល់ភាគីទាក់ទងនឹងសំណើរបស់សហមេធាវីសុំពន្យារពេលវេលាដើម្បីដាក់បណ្ដឹងឧទ្ធរណ៍ ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឱ្យចូលមើលសំណុំរឿង ឯកសារ D11/2/4/3 (ERN 00714762) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ ។

[11] ០០៣/០០៧-០៩-២០០៩-អវតក-កសចស(អជបប០១) "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្ដីពីភាពអាចទទួលយកបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted]" ឯកសារ D11/1/4/1 (ERN 00698346) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ។

១៧. នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted] បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពទទួលយកបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] ។

១៨. នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះនៅក្នុង "សេចក្តីជូនដំណឹងដល់ភាគីទាក់ទងនឹងសំណើរបស់សហមេធាវី" សុំពន្យារពេលសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ក្នុងពេលរង់ចាំការអនុញ្ញាតឱ្យចូលមើលសំណុំរឿង ("ការជូនដំណឹង") បានដាក់បញ្ចូលមន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីជាភាគីនៃដំណើរការនីតិវិធី[13] ។

## ២.២ ជនសង្ស័យនៅតែមិនទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពនៅឡើយ

១៩. នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១០ អតីតប្រធានអង្គភាពគាំពារការការពារក្តី ("DSS") [redacted] ក្នុងគោលបំណងការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងដើម្បីរៀបចំការការពារក្តីប្រកបដោយប្រសិទ្ធិភាពសម្រាប់ជនសង្ស័យនៅក្នុងសំណុំរឿងទាំងពីរនេះ[14] ។

២០. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ [redacted]

---

[12] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្តីពីភាពអាចទទួលយកបានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] (D11/2/3) (សំណុំរឿង ០០៣ និង ០០៤), ឯកសារ D11/1/4/2 (ERN 00693830) ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១ ។

[13] ០០៣/០០៧-០៩-២០០៩-អវតក-កសចស(អជប០២) "ការជូនដំណឹងដល់ភាគីទាំងអស់ទាក់ទងនឹងសំណើរបស់សហមេធាវីសុំពន្យារពេលសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ ក្នុងពេលរង់ចាំការអនុញ្ញាតឱ្យចូលមើលសំណុំរឿង" ឯកសារ D11/2/4/3 (ERN 00714762) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ ។

[14] [redacted]

[15] [redacted]

[redacted] ។

២១. នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១០ អតីតប្រធានអង្គភាពគាំពារការការពារក្តី បានបញ្ជូនអនុស្សរណៈមួយទៅការិយាល័យរដ្ឋបាល ដោយស្នើសុំឱ្យជួល [redacted] តាមលក្ខន្តិកៈការងារក្នុងចំណោមបញ្ហាផ្សេងទៀត ដូចខាងក្រោម:

ទីប្រឹក្សា [redacted] គឺត្រូវការចាំបាច់ដើម្បីជួយអង្គភាពគាំពារការការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈ:

- តំណាងឱ្យផលប្រយោជន៍របស់ជនសង្ស័យដែលមិនបង្ហាញអត្តសញ្ញាណ ដើម្បីធានាដល់ការគោរពសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។
- ផ្តល់ការប្រឹក្សា និងជំនួយផ្សេងទៀតដែលគម្រូវ នៅមុនពេលដែលសហមេធាវីត្រូវបានចាត់តាំងឱ្យជនសង្ស័យនិមួយៗនៅពេលណាមានការយកចម្លើយ ឬ ចាប់ខ្លួន[17] ។

២២. អនុប្រធានការិយាល័យរដ្ឋបាលយល់ព្រមលើកិច្ចសន្យាការងាររបស់ [redacted] ហើយ [redacted] បានចុះហត្ថលេខាលើកិច្ចសន្យាការងារ [redacted] និងចាប់ផ្តើមបំពេញការងារនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០[18]។

២៣. នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០ អតីតប្រធានអង្គភាពគាំពារការការពារក្តី បានចាត់តាំង [redacted] ជាមេធាវីតំណាងឱ្យផលប្រយោជន៍របស់ជនសង្ស័យមិនបង្ហាញអត្តសញ្ញាណនៅក្នុងសំណុំរឿង០០៣ និង ០០៤ រហូតដល់ពួកគេត្រូវបានចាត់តាំងមេធាវីរៀងៗខ្លួន តាមការជ្រើសរើសដោយខ្លួនឯង ។ ការចាត់តាំងនេះត្រូវបានបញ្ជាក់ជាផ្លូវការជាលាយលក្ខណ៍អក្សរដោយអង្គភាព

---

[16] អនុលោមតាមយុត្តិសាស្ត្ររបស់ អវតក លិខិតរបស់សហចៅក្រមស៊ើបអង្កេតមិនអាចបង្កើតបានជាដីកាសម្រេច ឬដីកាបង្គាប់ដែលចងកាតព្វកិច្ចឱ្យអនុវត្តបានទេ ។ សូមមើលការពិភាក្សាស្តីពីភាពខុសគ្នាអត្ថន័យផ្នែកច្បាប់រវាង"លិខិត" និង"ដីកាសម្រេច" នៅក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស, សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការរំលោភការសម្ងាត់នៃកិច្ចស៊ើបសួរ" របស់អង្គបុរេជំនុំជម្រះ ឯកសារ D138/1/8 (ERN 00349456) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ នៅកថាខណ្ឌទី ៤៣-៤៤ ។

[17] អនុស្សរណៈ "Consultancy: [redacted] (ប្រធានអង្គភាព DSS) ទៅកាន់ [redacted] (ប្រធានផ្នែកបុគ្គលិក នៃUNAKRT ) ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១០ ។

[18] [redacted] ។

00723682



គាំពារការការពារក្ដីដល់[redacted]នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១០[19] [redacted]១[20] ។

២៤. សហចៅក្រមស៊ើបអង្កេត មិនបានទាក់ទងមកអង្គភាពគាំពារការការពារក្ដីទាក់ទងនឹងការជូនដំណឹងពីការចាត់តាំងនេះទេ។ ក្នុងសេចក្ដីសម្រេចលើញត្តិដែលដាក់ដោយ[redacted] សហចៅក្រមស៊ើបអង្កេតបានដាក់បញ្ចូល[redacted]ជា "មេធាវីការពារផលប្រយោជន៍ជនសង្ស័យមិនបង្ហាញអត្តសញ្ញាណ"។ សេចក្ដីសម្រេចនេះបានចេញបន្ទាប់ពីការជូនដំណឹងអំពីការចាត់តាំងនេះ[21] ។

២៥. កិច្ចសន្យាការងារលើកដំបូងរបស់[redacted]ផុតកំណត់នៅថ្ងៃទី៣០ មេសា ឆ្នាំ២០១១ ។ មន្ត្រីទទួលបន្ទុកប្រចាំអង្គភាពគាំពារការការពារក្ដី បានបញ្ជូនអនុស្សរណៈចំនួនពីរទៅអនុប្រធានការិយាល័យរដ្ឋបាល គឺមួយនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១[22] និងមួយទៀតនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១[23] ដោយបានស្នើសុំឱ្យបន្តកិច្ចសន្យាការងាររបស់[redacted]។

២៦. អនុប្រធានការិយាល័យរដ្ឋបាលមិនយល់ព្រមបន្តកិច្ចសន្យានេះទេ ហើយបានស្នើឱ្យអង្គភាពគាំពារការការពារក្ដី ផ្ដល់ការពន្យល់ និងអំណះអំណាងបន្ថែមទៀត ។ ដើម្បីអនុវត្តតាមការស្នើសុំនេះ

---

[19] "លិខិតចាត់តាំង" ដោយ Rupert Abbott (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្ដី) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ ។

[20] [redacted]

[21] ០០៣/០០៧-០៩-២០០៩-អវតក-កសចស "កោលលុបចោលចំណងជើង", សហចៅក្រមស៊ើបអង្កេត, ឯកសារ D3/1 (ERN 00658678) ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១[redacted]

[22] អនុស្សរណៈ: "អង្គភាពគាំពារការការពារក្ដី-សំណើសុំបន្តកិច្ចសន្យា consultancy សម្រាប់[redacted]" ដោយអ្នកនាង Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្ដី) ចុះថ្ងៃទី៣ ខែ ឧសភា ឆ្នាំ២០១១ ។

[23] អនុស្សរណៈ: "អង្គភាពគាំពារការការពារក្ដី-សំណើសុំបន្តកិច្ចសន្យា consultancy សម្រាប់[redacted]" ដោយអ្នកនាង Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្ដី) ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ២០១១ ។

00723683



អនុស្សរណៈទីបីត្រូវបានដាក់ទៅអនុប្រធានការិយាល័យរដ្ឋបាលនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១[24] ហើយសំណើរបស់អង្គភាពគាំពារការការពារក្តី មិនទាន់សម្រេចនៅឡើយទេ ។

២៧. បើតាមអង្គភាព គាំពារការការពារក្តី បានដឹង [redacted] មិនទាន់ត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ នៅឡើយទេ ។

២៨. បើតាមអង្គភាពគាំពារការការពារក្តី បានដឹងជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ០០៤ នៅតែពុំទាន់ទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពនៅឡើយទេ ។

២៩. នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីបានដាក់អនុស្សរណៈមួយមានចំណងជើងថា "អង្គភាពគាំពារការការពារក្តីនឹងបង្ហាញបញ្ជីឈ្មោះមេធាវីជាតិ និងមេធាវីអន្តរជាតិដល់ជនសង្ស័យ [redacted] (សំណុំរឿង០០៣) អនុលោមតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុងរបស់ អវតក[25] ដែលនៅក្នុងអនុស្សរណៈនេះអ្នកនាងបាន:

i. ជូនដំណឹងជាបន្ទាន់ដល់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតថាអង្គភាពគាំពារការការពារក្តី នឹងខិតខំខ្នះខ្នែងបង្ហាញបញ្ជីឈ្មោះមេធាវីជាតិ និងមេធាវីអន្តរជាតិដល់លោក [redacted] ។

ii. ជូនដំណឹងជាបន្ទាន់ដល់ការិយាល័យរដ្ឋបាលថាអង្គភាពគាំពារការការពារក្តី ត្រូវការជំនួយផ្នែករដ្ឋបាល និងពស្តុភារដើម្បីគាំទ្រដល់ការស្វែងរកលោក [redacted] និងដើម្បីបង្ហាញដល់ពួកគាត់នូវបញ្ជីឈ្មោះមេធាវី និងបានភ្ជាប់សំណើសុំបេសកម្មពីរទាក់ទងនឹងបញ្ហានេះ និង

iii. ស្នើសុំសហចៅក្រមស៊ើបអង្កេតផ្តល់ជាបន្ទាន់នូវព័ត៌មានណាមួយ ឱ្យបានឆាប់បំផុតតាមតែអាចធ្វើបាន ដែលអាចជួយដល់អង្គភាព DSS នៅក្នុងការស្វែងរកជនសង្ស័យទាំងពីររូបនេះ ។

---

[24] អនុស្សរណៈ: "ការធ្វើយុត្តិកម្មសម្រាប់ការបន្តកិច្ចសន្យារបស់ [redacted]" ដោយអ្នកនាង Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្តី) ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១ ។

[25] អនុស្សរណៈ: "អង្គភាពគាំពារការការពារក្តីបង្ហាញបញ្ជីឈ្មោះមេធាវីជាតិ និងមេធាវីអន្តរជាតិដល់ជនសង្ស័យ [redacted] (សំណុំរឿង ០០៣) អនុលោមតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុងរបស់ អវតក" ដោយអ្នកនាង Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្តី) ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ ។

៣០. ទោះបីជាសំណើរបស់អង្គភាពគាំពារការការពារក្តីសុំជំនួយផ្នែករដ្ឋបាល និងពស្តុភារជាសំណើបន្ទាន់ក៏ដោយ សំណើនេះមិនទាន់ត្រូវបានគេសម្រេចនៅឡើយទេ ហើយក៏គ្មានការជូនដំណឹងណាមួយត្រូវបានផ្តល់ឲ្យដើម្បីជួយអង្គភាពនេះក្នុងការស្វែងរកជនសង្ស័យទាំងពីររូបនេះដែរ។

## III. សារណា

### <u>៣.១ អង្គភាពគាំពារការការពារក្តី មានមូលដ្ឋានដើម្បីដាក់ញត្តិនេះនៅចំពោះមុខអង្គបុរេជំនុំជម្រះ</u>

៣១. អង្គបុរេជំនុំជម្រះបានបញ្ចូលមន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី នៅលើទំព័រមុខនៃសេចក្តីជូនដំណឹង ហេតុដូច្នេះបានកំណត់នាងជាភាគីមួយនៃដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ភាគី ទាំងអស់នៃដំណើរការនីតិវិធីរួមទាំងមេធាវីការពារក្តីផង មានសិទ្ធិធ្វើសារណាឆ្លើយតបទៅនឹងការដាក់ឯកសាររបស់ភាគីដទៃទៀត[26] ឬដាក់សំណើសមហេតុផលសុំបន្ថែមពេលវេលាកំណត់[27] និងចំនួនសន្លឹក[28] ដែលចាំបាច់ដើម្បីធានាដល់ដំណើរការនីតិវិធីនៅចំពោះមុខ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ។

៣២. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី មានមូលដ្ឋានដើម្បីដាក់ញត្តិនេះនៅចំពោះអង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានយល់ឃើញពីលើកមុនថាសំណើសុំផ្អាកនីតិវិធីអាចស្ថិត "នៅក្នុងដែនកំណត់ទូទៅនៃពាក្យបណ្តឹងណាមួយដែលស្ថិតនៅក្រោមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់បង្កើតអវតក") ដែលក្នុងនោះចែងពាក់ព័ន្ធថា "ការជំនុំ ជម្រះត្រូវតែយុត្តិធម៌" និងត្រូវតែប្រព្រឹត្តទៅ "ដោយគោរពយ៉ាងពេញលេញទៅលើសិទ្ធិរបស់ជនជាប់ចោទ..."[29] ។

៣៣. សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថាពួកគេចាត់ទុកថា "គោលការណ៍ច្បាប់ដែលអនុវត្ត

---

[26] មាត្រា ៨.៣ និង ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក ។ (អវតក/០១/២០០៧/វិសោធនកម្មលើកទី៦) ។

[27] វិធាន ៣៩(៤)(ក) នៃវិធានផ្ទៃក្នុង ។

[28] មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក (អវតក/០១/២០០៧/វិសោធនកម្មលើកទី៦)។

[29] សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៤២) "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធចោលសំណើសុំផ្អាកនីតិវិធីដោយមូលដ្ឋាននៃការរំលោភដំណើរ (D264/1) ឯកសារលេខ D264/2/1 (ERN 00543789) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ នៅកថាខណ្ឌទី១៣ ។

ចំពោះសំណើសុំមោឃៈភាព និងច្បាប់ដែលអនុវត្តចំពោះសំណើសុំផ្អាកនីតិវិធី គឺដូចគ្នា ជាពិសេសសំណើទាំងពីរនេះផ្អែកលើអង្គហេតុតែមួយ" ហើយដូច្នេះ ការផ្អាកដំណើរការនីតិវិធីអាចអនុញ្ញាតនៅករណីមានមានកំហុសនីតិវិធី ឬនឹងកើតឡើងនូវកំហុសនីតិវិធី បើសិនការផ្អាកដំណើរការនីតិវិធីមិនត្រូវបានអនុញ្ញាតនោះ និង "នៅពេលដែលកំហុសនីតិវិធីរំលោភលើសិទ្ធិរបស់ភាគីដែលដាក់សំណើសុំ"[30]។

៣៤. ការសំអាងហេតុស្រដៀងនេះ ត្រូវបានប្រើនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី("ICTY") ដើម្បីបង្គាប់ឲ្យផ្អាកនីតិវិធី ជាពិសេសក្នុងករណីដែលការជំនុំជម្រះក្តីដោយយុត្តិធម៌មិនអាចសម្រេចទៅបានដោយគ្មានការផ្អាកនីតិវិធីនោះ[31] ឬនៅករណីដែលការបន្តនីតិវិធី នឹងរំលោភដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ[32] ។

៣៥. សន្ទត់ថាមន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី ត្រូវបានបញ្ចូលជាភាគីនៃដំណើរការនីតិវិធី ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ អនុលោមតាមវិធាន ២១ (១) នៃវិធានផ្ទៃក្នុង និងមាត្រា៣៣ថ្មី និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក ។ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី បានសម្រេចថាការផ្អាកដំណើរការនីតិវិធី គឺចាំបាច់ដើម្បីឲ្យអង្គភាពគាំពារការការពារក្តី ជាមួយនឹងការគាំទ្រពីការិយាល័យរដ្ឋបាល ចាត់វាល់វិធានការចាំបាច់ទាំងអស់ដើម្បីអនុញ្ញាតឲ្យជនសង្ស័យអនុវត្តសិទ្ធិស្របច្បាប់របស់ពួកគេក្នុងការទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាព ។

---

[30] សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស "ដីកាបដិសេធលើសំណើសុំមោឃៈភាព និងសំណើសុំផ្អាកដំណើរការនីតិវិធីដោយមូលហេតុរំលោភដំណើរការ ដាក់ដោយ អៀង ធិរិទ្ធ" ឯកសារ D264/1 (ERN 00422607-00422618) នៅកថាខណ្ឌទី៣០- ការដាក់ឯកសារសម្ងាត់ដែលសំអាងនៅក្នុង ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៧១) "បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់ អៀង សារី ទៅនឹងសារណាតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា និងការកត់សម្គាល់បន្ថែម និងសំណើសុំផ្អាកនីតិវិធី" ឯកសារ D390/1/2 (ERN 00598685) ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ នៅកថាខណ្ឌទី៣ អក្សរក្នុងលេខយោងលេខ ៦ ។

[31] រឿងក្តីរវាងរដ្ឋអាជ្ញា តទល់ *Dusko Tadic*, IT-94-1-A, "សាលក្រម" តុលាការកំពូលចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ នៅកថាខណ្ឌទី៥៥ ។

[32] រឿងក្តីរវាងរដ្ឋអាជ្ញា តទល់ *Janko Bobetko*, IT-02-62-AR54ស្ទួន, "សេចក្តីសម្រេចលើការជំទាស់ដោយក្រូអាតទៅនឹងសេចក្តីសម្រេច និងដីកាសម្រេចពីការបញ្ជាក់គាំទ្រចៅក្រម" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ នៅកថាខណ្ឌទី១៥ ។

00723686



## ៣.២ ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ មានសិទ្ធិជាមូលដ្ឋានទទួលបានការតំណាងផ្នែកច្បាប់:

៣៦. ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ មានសិទ្ធិជាមូលដ្ឋានទទួលបានការតំណាងផ្នែកច្បាប់ អនុលោមតាមច្បាប់បង្កើត អវតក[33], វិធានផ្ទៃក្នុង[34] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[35] ("ICCPR") ដែលដាក់បញ្ចូលនៅក្នុងក្របខណ្ឌច្បាប់របស់[36] អវតក និងរដ្ឋធម្មនុញ្ញកម្ពុជា[37] ។

៣៧. មាត្រា ២៤ នៃច្បាប់បង្កើត អវតក ចែងថា:

> *ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារក្តីពីមេធាវី ដែលជ្រើសរើសដោយខ្លួនឯងដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ "ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែផ្ទាល់មាត់ជាភាសាដែលជនសង្ស័យនិយាយ និងយល់បាន ។* (បញ្ជាក់បន្ថែម) ។

៣៨. វិធាន ២១(១) នៃវិធានផ្ទៃក្នុងធានាថា "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ [...] ត្រូវបានការពារដោយមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន" (បញ្ជាក់បន្ថែម) ។

៣៩. ម្យ៉ាងទៀតវិធាន២១(១)នៃវិធានផ្ទៃក្នុងចែងថា "បទបញ្ញត្តិទាំងអស់នៅជាធរមានត្រូវតែបកស្រាយក្នុងន័យការពារ *ជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនត្រូវចោទ និង ជនរងគ្រោះ"* (បញ្ជាក់បន្ថែម") ។

៤០. នៅក្នុងសន្ទានុក្រមរបស់វិធានផ្ទៃក្នុង, "ជនសង្ស័យ" ត្រូវបានកំណត់និយមន័យថាជាបុគ្គលដែលសហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត ចាត់ទុកថាធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ ។

៤១. បន្ថែមពីលើនេះ មាត្រា ៣៣ថ្មី នៃច្បាប់បង្កើត អវតក អនុវត្តចំពោះដំណើរការនីតិវិធីទាំងអស់នៅ

---

[33] មាត្រា ២៤, ៣៣ថ្មី និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក ។

[34] វិធាន ២១ នៃវិធានផ្ទៃក្នុង ។

[35] មាត្រា ១៤ និង មាត្រា១៥ ICCPR ។

[36] មាត្រា ៣៣ថ្មី និង មាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក, មាត្រា ១២ និង មាត្រា ១៤ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ។

[37] មាត្រា ៣១ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។

អវតក បទដ្ឋានអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ខណៈដែលមាត្រា ៣៥ថ្មីចែងពីការធានាជាអប្បបរមានៃការជំនុំជម្រះដោយយុត្តិធម៌ ដែលរួមបញ្ចូលៈ

> ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន ។
>
> មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសរើសដោយខ្លួនឯង ។
>
> ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ និងទទួលបាននូវជំនួយផ្នែកច្បាប់ដោយឥតថ្លៃ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលដោយខ្លួនឯង[38]។

៤២. គេទទួលស្គាល់ថាក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការការពារពេញលេញចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌គឺយកមកអនុវត្តចាប់តាំងពីពេលដែលជនសង្ស័យប្រឈមនឹង"ការចោទប្រកាន់"។ សន្ធានុក្រមនៃវិធានផ្ទៃក្នុងបានឲ្យនិយមន័យ "ជនត្រូវចោទ" ថាជា "បុគ្គលម្នាក់ដែលត្រូវចោទប្រកាន់ចំពោះរឿងក្តីណាមួយក្នុងចន្លោះពីពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់"។

៤៣. សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា "បុគ្គលណាមួយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវចាត់ថាជា "ជនត្រូវចោទ"[39] ។ ជំហរនេះស៊ីចង្វាក់ជាមួយយុត្តិសាស្ត្របារាំងដែលលើកមកសំអាងដោយសហចៅក្រមស៊ើបអង្កេត[40] ។

---

[38] មាត្រា ៣៥ថ្មី(ក), (ខ) និង(ឃ) នៃច្បាប់បង្កើត អវតក ។

[39] ០០២/១៩-០៩-២០០៧-អវតក-កសចស, "ដីកាបដិសេធសំណើសុំចោទប្រកាន់បន្ថែម, សហចៅក្រមស៊ើបអង្កេត, ឯកសារ D298/2 (ERN 00476085), ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌទី១៣ (ជើងទំព័រទី៦) ។

[40] [...] បុគ្គលណាមួយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទោះបីជានៅពេលដែលគាត់ត្រូវបានចាត់ទុកថាជា "x ដែលត្រូវបង្ហាញខ្លួនជា..." គឺត្រូវបានចាត់ទុកជាជនត្រូវចោទដោយស្វ័យប្រវត្តិ ដោយមិនគិតពីថ្ងៃដែលបុគ្គលនោះត្រូវបានជូនដំណឹងអំពីការចោទប្រកាន់ដោយចៅក្រមស៊ើបអង្កេតឡើយ""Crim. 5 nov. 1985: Bull. Crim. No 244; D. 186. IR. 303, obs. Pradel; JCP 1986 II. 20685 កត់សម្គាល់ [ការបកប្រែរបស់] Jeandidier៖ ដែលបានសំអាងក្នុងសំណុំរឿង

៤៤. ការអនុវត្តទស្សនទាននៃ "ការចោទប្រកាន់" មានឫសគល់នៅក្នុងបរិបទសិទ្ធិជាមូលដ្ឋានទទួលបានការជំនុំជម្រះដោយយុត្តិធម៌[41] ។ តុលាការអឺរ៉ុបសិទ្ធិមនុស្ស ("EctHR") យល់ឃើញថាៈ

> "ចំណុចដ៏លេចធ្លោនៅក្នុងសង្គមប្រជាធិបតេយ្យតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គាំទ្រដល់ការយល់ឃើញនៃ "ការចោទប្រកាន់" ជាក់ស្តែង ជាជាង "ការចោទប្រកាន់" "ផ្លូវការ" ដែលមានយោងនៅក្នុងមាត្រា៦ ។ វាបង្ខំឱ្យតុលាការពិនិត្យមើលឲ្យហួសពីអាការៈពីខាងក្រៅ និងពិនិត្យពីតថភាពរបស់នីតិវិធីដែលជាចោទជាបញ្ហា ដើម្បីសម្រេចថាតើមានការចោទប្រកាន់មាននៅក្នុងអត្ថន័យនៃមាត្រា ៦ ដែរ ឬអត់[42] ។

៤៥. អនុលោមតាមយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសិទ្ធិមនុស្ស("ECtHR") ស្ថានភាពរបស់ជនសង្ស័យបានបំពេញទស្សនទាននៃ "ការចោទប្រកាន់" ជាក់ស្តែង សម្រាប់គោលបំណងនៃការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ប្រសិនបើ៖

ក. ការជូនដំណឹងជាផ្លូវការដោយអាជ្ញាធរមានសមត្ថកិច្ចអំពីការចោទប្រកាន់ទៅបុគ្គលម្នាក់ដែលថាគាត់បានប្រព្រឹត្តបទល្មើស ឬ

ខ. មានលេចឡើងនូវវិធានការដទៃទៀតដែលថ្លែងបញ្ជិតបញ្ចៀងដល់ការចោទប្រកាន់ ហើយដែលបានប៉ះពាល់ជាដុំកំភួនដល់ស្ថានភាពរបស់ជនសង្ស័យ[43]។

៤៦. យោងតាមលក្ខខណ្ឌ (ក) ខាងលើ សន្ធានុក្រមនៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត និងយុត្តិសាស្ត្របារាំង សុទ្ធតែឲ្យនិយមន័យ "ជនត្រូវចោទ"ថាជាបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងដីកា

---

០០២/១៩-០៩-២០០៧-អវតក-កសចស, "ដីកាបដិសេធសំណើសុំចោទប្រកាន់បន្ថែម, សហចៅក្រមស៊ើបអង្កេត, ឯកសារ D298/2 (ERN 00476085), ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌទី១៣ (ជើងទំព័រទី៦) ។

[41] សូមមើលផងដែរ Stephanos Stavros "ការធានាចំពោះជនសង្ស័យដែលត្រូវចោទប្រកាន់ក្រោមមាត្រា៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស៖ការវិភាគអំពីការអនុវត្តន៍សិទ្ធិសញ្ញា និងការប្រៀបធៀបជាមួយលិខិតុបករណ៍ដទៃទៀត" Martinus Nijhoff, Dordrecht, 1993, នៅទំព័រ ៨៣ "អនុសញ្ញាមានបំណងការពារបុគ្គលប្រឆាំងនឹងការដែលមានការសង្ស័យជាដុំកំភួនប្រឆាំងនឹងគាត់ក្នុងរយៈពេលយ៉ាងយូរដោយមិនសមហេតុផលនិងដោយគ្មានការសម្រេចអ្វីសោះ ។ ការចេះតែសង្ស័យបែបនេះ ជាពិសេសប្រសិនបើវាសាយភាយដល់សាធារណៈជន វាបង្កឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍, សតិអារម្មណ៍ ព្រមទាំងសម្ភារៈ និងមនុស្សក្នុងក្រុមគ្រួសាររបស់គាត់ ។

[42] រឿងក្តី Adolf តទល់នឹងប្រទេស Austria (១៩៨២) 4 EHRR 313 នៅកថាខណ្ឌទី៣០ ។

[43] រឿងក្តី Adolf ទល់នឹងប្រទេស Austrial (១៩៨២) 4EHRR 313, កថាខណ្ឌទី៣០។

---

00723689



សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។

៤៧. យោងតាមលក្ខខណ្ឌ (ខ) ដែលអាចត្រូវបានបំពេញដោយឯករាជ្យពីអត្ថិភាពនៃ"ការជូនដំណឹងផ្លូវការ" ពាក្យថា "ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" សំដៅដល់ផលលំបាកដែលបង្ករឡើងដោយសកម្មភាពចោទប្រកាន់ និង/ឬសកម្មភាពស៊ើបអង្កេត ទៅលើផលប្រយោជន៍បុគ្គល និងផលប្រយោជន៍ផ្នែកច្បាប់របស់ជនសង្ស័យ[44]។

៤៨. កត្តាទាំងខាងក្រោមនេះ បាននាំឱ្យមានការលើកឡើងដោយប្រយោលអំពីការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌប្រឆាំងជនសង្ស័យក្នុងសំណុំរឿង 00៣ ហើយបានប៉ះពាល់យ៉ាងខ្លាំងដល់ផលប្រយោជន៍របស់ពួកគេ៖

ក. [redacted]

---

[44] *Eckle ទល់នឹងប្រទេសអាល្លឺម៉ង់* ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨២ នៅកថាខណ្ឌទី៧៤ដែលនៅទីនោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានប្រកាន់ខ្ជាប់ដើម្បីយកទៅអនុវត្ត មិនត្រឹមតែនៅពេលមានការជូនដំណឹងជាផ្លូវការអំពីបទចោទប៉ុណ្ណោះទេ ប៉ុន្តែចាប់តាំងពីការចាប់ផ្តើមស៊ើបអង្កេតបឋមផងដែរ ។

[45] [redacted]

[46] [redacted]

[47] សេចក្តីប្រកាសព័ត៌មាន: សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១១ "ដោយសារតែសហចៅក្រមស៊ើបអង្កេតមានព័ត៌មានដែលអាចជឿជាក់បានថាខ្លឹមសារនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

00723690



[redacted] ។ កត្តាទាំងនេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានពិរុទ្ធរបស់ជនសង្ស័យ[49] និងសិទ្ធិរបស់ជនសង្ស័យទទួលបានការជូនដំណឹងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំនួរ[50]។ កត្តាទាំងនេះបង្កើតឱ្យមានតម្រូវការចាំបាច់ចំពោះការការពារក្តីប្រកបដោយប្រសិទ្ធិភាពដើម្បីធានាដល់សិទ្ធិទាំងនេះ និងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ផ្សេងទៀត ។

ខ. សិទ្ធិជាមូលដ្ឋានរបស់ជនសង្ស័យចំពោះសមភាពនៃមធ្យោបាយតតាំងក្តី ត្រូវបាន និងបន្តប៉ះពាល់ដោយការដកមេធាវីការពារក្តីចេញពីការចូលរួមក្នុងការស៊ើបអង្កេតរយៈពេល ២០ខែ និងសិទ្ធិស្នើសុំកិច្ចស៊ើបសួរបន្ថែមទៀត ក៏ដូចជាការដកសិទ្ធិឆ្លើយតបទៅនឹងសារណារបស់ភាគី[51] ឬបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដែលធ្វើឡើងក្នុងអំឡុងពេលស៊ើបអង្កេត និងបន្ទាប់ពីការបិទការស៊ើបអង្កេត។ គេគួរសង្កត់ធ្ងន់ផងដែរថានៅក្នុងសារណារបស់ខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ ភាគីបានលើកឡើងពីបញ្ហាអង្គច្បាប់ជាច្រើន និងបានធ្វើការចោទប្រកាន់ដោយផ្អែកលើអង្គហេតុដែលសមតែទទួលបានការត្រួតពិនិត្យពីមេធាវីការពារក្តី ។

គ. ការដែលថាបុគ្គលចំនួន ៣១៨ នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

លើកទី២ ត្រូវបានបញ្ចេញដោយដោយបុគ្គលិកមិនស្មោះត្រង់ម្នាក់នៅ អវតក សហចៅក្រមស៊ើបអង្កេតសូមព្រមានថាជនណាដែលចុះផ្សាយព័ត៌មានចេញពីឯកសារសម្ងាត់នេះ នឹងត្រូវទទួលខុសត្រូវចំពោះនីតិវិធីពីបទជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់តុលាការស្របតាមវិធាន៣៥នៃវិធានផ្ទៃក្នុង"។

[48] [redacted]

[49] Stavros សូមមើលអក្សរក្នុងលេខយោងលេខ ៤២ ខាងលើ ។

[50] វិធាន២១(១) (គ)នៃវិធានផ្ទៃក្នុង។

[51] កថាខណ្ឌទី៦ ដល់ទី១៨ខាងលើនៃញត្តិនេះ។

00723691



ក្នុងសំណុំរឿង ០០៣[52] ហើយបើយោងតាមវិធានផ្ទៃក្នុង[53] និងក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រព័ន្ធច្បាប់ស៊ីវិល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចចូលពិនិត្យមើលសំណុំរឿងបាន[54] ដូច្នេះហើយវារឹតតែធ្វើឱ្យប៉ះពាល់បន្ថែមទៀតដល់សមភាពនៃមធ្យោបាយតតាំងក្តីរបស់ជនសង្ស័យ ដោយមិនបានផ្តល់ឱ្យពួកគេនូវដំណោះស្រាយជាសិទ្ធិខាងនីតិវិធីដូចក្នុងប្រពន្ធច្បាប់ស៊ីវិលដទៃទៀតឡើយ[55] ។

៤៩. ដូច្នេះ ជនសង្ស័យក្នុងសំណុំរឿង០០៣ មានសិទ្ធិជាមូលដ្ឋានទទួលបានការតំណាងផ្នែកច្បាប់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

ក. មាត្រា២៤ នៃច្បាប់ស្តីពីការបង្កើត អវតក ស្របជាមួយ វិធាន២១ (១) នៃវិធានផ្ទៃក្នុង និងសន្ទានុក្រមនៃវិធានផ្ទៃក្នុង ចែងយ៉ាងច្បាស់ទាក់ទងនឹងសិទ្ធិទទួលបានការការពារក្តីដោយខានពុំបានរបស់ជនសង្ស័យ។

ខ. បន្ថែមពីលើនេះ ជនសង្ស័យមានសិទ្ធិទទួលបានតំណាងផ្នែកច្បាប់អនុលោមតាមសិទ្ធិជាមូលដ្ឋានរបស់ពួកគេក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលអាចយកមកអនុវត្ត តាមរយៈការកើតឡើងនៃវិធានការនានាដែលឈានដល់ការចោទប្រកាន់ពីបទចោទព្រហ្មទណ្ឌប្រឆាំងជនសង្ស័យ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ផលប្រយោជន៍របស់ពួកគេ[56]។

## ៣.៣ ការិយាល័យរដ្ឋបាលនៅ អវតក មានកាតព្វកិច្ចគាំទ្រសិទ្ធិទទួលបានតំណាងផ្នែកច្បាប់របស់

---

[52] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត។

[53] វិធាន២៣ ស្ទួន(២) នៃវិធានផ្ទៃក្នុង។

[54] មាត្រា ១១៤ កថាខណ្ឌទី៥-១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ។ សូមមើលផងដែរ Frédérique Agostini, 'Les droits de la partie civile dans le proces pénal', Rapport Annuel de la Cour de Cassation, 2000 ។

[55] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងបានផ្តល់ដំណោះស្រាយជានព្រាស្រ័យនៃវិសមភាពនេះដោយដាក់ឈ្មោះបុគ្គលដែលត្រូវដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថាជា "ដែលត្រូវបានចោទ" « *Une personne qui a été personnellement mise en cause dans une plainte avec constitution de partie civile et contre laquelle le ministère public a requis, nommément, l'ouverture d'une information est partie à l'instance et doit être considérée comme inculpée* » : Crim. 24 mai 1971 : Bull. crim. n. 171 ដកស្រង់ Dalloz ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង, បោះពុម្ពផ្សាយឆ្នាំ២០០៩, ទំព័រ៣១៤

[56] សូមមើលផងដែរ មាត្រា៥៦(២) (គ) នៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងកថាខណ្ឌ១៤០ និង១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាឡឺម៉ង់។

00723692



__ជនសង្ស័យ__

៥០. វិធាន២២(១) នៃវិធានផ្ទៃក្នុងចែងថា៖

> ជនណាដែលមានសិទ្ធិទទួលបានមេធាវីស្ថិតនៅក្រោមវិធានផ្ទៃក្នុងនេះ ត្រូវមានសិទ្ធិទទួលបានជំនួយពីមេធាវីជាតិ ឬ មេធាវីអន្តរជាតិដោយសហការជាមួយមេធាវីជាតិ ទៅតាមការជ្រើសរើសដោយផ្ទាល់ខ្លួនរបស់ពួកគេ តាមបែបបទដូចខាងក្រោម:
>
> [...]
>
> ជនក្រីក្រដែលមានសិទ្ធិទទួលបានការតំណាង ឬ ជំនួយតាមផ្លូវច្បាប់ក្រោមវិធានទាំងនេះ ត្រូវមានសិទ្ធិជ្រើសរើស ដោយសេរីពីក្នុងចំណោមមេធាវីជាតិ និង អន្តរជាតិដែលមានក្នុងបញ្ជីដូចមានចែងក្នុងវិធាន១១ (២) (ឃ)។

៥១. ការកំណត់ជាបឋមទាក់ទងនឹងបញ្ហាថាតើបុគ្គលម្នាក់មានសិទ្ធិទទួលបានមេធាវី អនុលោមតាមវិធានផ្ទៃក្នុង គឺជាបញ្ហាសំខាន់ក្នុងការការពារក្តីដែលស្ថិតនៅក្រោមស្វ័យភាពរបស់អង្គភាពគាំពារការការពារក្តី ស្របតាមវិធាន ១១ (១) នៃវិធានផ្ទៃក្នុង ហើយមិនស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែករដ្ឋបាលឡើយ:

> ការិយាល័យរដ្ឋបាលត្រូវ បង្កើតអង្គភាពគាំពារការការពារក្តីដែលមានស្វ័យភាពលើបញ្ហាសំខាន់ក្នុងការការពារក្តីប៉ុណ្ណោះ ដូចមានចែងក្នុងវិធាននេះ។

៥២. បញ្ញត្តិនេះឆ្លុះបញ្ចាំងពីគោលការណ៍ស្ថាបនិកមួយក្នុងចំណោមគោលការណ៍ស្ថាបនិកជាច្រើនទៀតទាក់ទងនឹងរចនាសម្ព័ន្ធរបស់ អវតក ដែលបានលើកឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងរបាយការណ៍ឆ្នាំ ២០០៤ របស់លោកស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម :

> ប្រព័ន្ធជំនួយផ្នែកច្បាប់របស់អង្គជំនុំជម្រះនឹងត្រូវបានចាត់ចែងដោយអង្គភាពគាំពារការការពារក្តីតូចមួយដែលមានស្វ័យភាពដាច់ពីការិយាល័យរដ្ឋបាល [...][57]។

៥៣. អំណាចរបស់របស់មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី ដើម្បីចាត់តាំងមេធាវីមានចែងក្នុងវិធាន១១ (៦) នៃវិធានផ្ទៃក្នុង :

> ប្រធានអង្គភាពគាំពារការការពារក្តីត្រូវសម្រេចអំពីជនណាមួយជាជនក្រីក្រ និងចាត់តាំង

[57] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម,A/59/432/ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤, កថាខណ្ឌទី៣៥។

00723693



មេធាវីការពារជនក្រីក្រ [...]។

៥៤. អំណាចនេះត្រូវបានបញ្ជាក់គាំទ្រដោយប្រធានអង្គជំនុំជម្រះសាលាដំបូង ("អជប") នៃ អវតក កាលពីថ្ងៃទី ៦ ខែសីហា ឆ្នាំ២០១០[58]។ករណីយុត្តិសាស្ត្រនៅ អវតក អនុញ្ញាតឱ្យមន្ត្រីទទួលបន្ទុកនៃអង្គភាពគាំពារការការពារក្តី ធ្វើសេចក្តីសម្រេចចាត់តាំងមេធាវីការពារក្តី ខណៈពេលដែលអង្គជំនុំជម្រះពាក់ព័ន្ធដទៃទៀតគ្រាន់តែធ្វើការ "កត់សម្គាល់" ពីការចាត់តាំងមេធាវីការពារក្តី "*ដោយឈរលើមូលដ្ឋាននៃសេចក្តីសម្រេចនេះ*"[59] តែប៉ុណ្ណោះ។

៥៥. សម្រាប់គោលបំណងទាំងនេះ វិធាន១១ (២) នៃវិធានផ្ទៃក្នុងចែងថា[60]:

អង្គភាពគាំពារការការពារក្តីត្រូវបំពេញមុខងារដូចខាងក្រោម:

[...]

ដោយស្ថិតនៅក្រោមការឃ្លាំមើលរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប បង្ហាញបញ្ជីឈ្មោះមេធាវី ដូចមានចែងក្នុងអនុវិធាន២ ចំណុច (គ) និង (ឃ) ទៅដល់បុគ្គលដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី ស្របតាមវិធានផ្ទៃក្នុងនេះ។

៥៦. ជាងនេះទៅទៀត អនុលោមតាមវិធាន១១(២) (ឆ) នៃវិធានផ្ទៃក្នុង :

អង្គភាពគាំពារការការពារក្តីត្រូវបំពេញមុខងារដូចខាងក្រោម:

[...]

ធ្វើកិច្ចសន្យាជាមួយមេធាវីការពារក្តី ដែលការពារពាល់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ ដែលក្រីក្រ ឬបុគ្គលដទៃទៀតដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី ស្របតាមវិធានផ្ទៃក្នុងនេះ។

---

[58] ០០១/១៨-៧-២០០៧/អវតក/អជស "ការជូនដំណឹងអំពីការចាត់តាំងសហមេធាវី" អង្គជំនុំជម្រះសាលាដំបូង, ឯកសារ E189 (ERN 00581354) ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១០ : លោក កង ឫទ្ធារី ត្រូវបានចាត់តាំងឱ្យធ្វើជាសហមេធាវីជាតិទី២ ដោយលោក Richard Rogers អតីតប្រធានអង្គភាពគាំពារការការពារក្តី។ ចៅក្រមបានកត់សម្គាល់ពីការតែងតាំងនេះដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចរបស់លោក Richard Rogers។

[59] *ដូចគ្នា*។

[60] វាច្បាស់ណាស់ថាពាក្យថា "ស្ថិតក្រោមការឃ្លាំមើល" ក្នុងវិធាន១១ (២)(ង) នៃវិធានផ្ទៃក្នុង គឺគ្រាន់តែចង់ធានាថាការប្រគល់បញ្ជីឈ្មោះមេធាវីទៅឱ្យជនសង្ស័យត្រូវបានធ្វើឡើងដោយត្រឹមត្រូវ និងបានដឹងឮដោយ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលពាក់ព័ន្ធប៉ុណ្ណោះ។

00723694



៥៧. កិរិយាសព្ទពិសេសបង្គាប់បញ្ជា "ត្រូវតែ" ដែលប្រើក្នុងបទបញ្ញត្តិទាំងនេះបានបង្កើតកាតព្វកិច្ចមួយដល់មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី ក្នុងការចាត់វិធានការណ៍ដើម្បីធានាឱ្យមានការការពារក្តីជូនអ្នកដែលមានសិទ្ធិទទួលបានការការពារក្តីនៅក្រោមច្បាប់នេះ។

៥៨. ដូចក្នុងសំណុំរឿងបច្ចុប្បន្ននេះ ខណៈពេលដែលមន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីបានសម្រេច ដោយអនុលោមតាមបទបញ្ញត្តិនៃក្របខណ្ឌច្បាប់នៅ អវតក ថាបុគ្គលមួយចំនួនមានសិទ្ធិទទួលបានជំនួយពីមេធាវី នោះមន្ត្រីទទួលបន្ទុកមានកាតព្វកិច្ចចាប់ផ្តើមនីតិវិធីដើម្បីជូនដំណឹងដល់បុគ្គលទាំងនោះអំពីសិទ្ធិរបស់ពួកគេ វាយតម្លៃពីភាពក្រីក្ររបស់ពួកគេដើម្បីសម្រេចថាតើពួកគេមានសិទ្ធិទទួលបានមេធាវីការពារក្តីដែលផ្តល់ថវិកាដោយតុលាការ[61]ដែរឬទេ និងចាត់តាំងមេធាវីដែលពួកគេជ្រើសរើសដោយខ្លួនឯង តាមករណីសមស្រប ។

៥៩. ជំហានដំបូងក្នុងនីតិវិធីនេះគឺការទំនាក់ទំនងលើកដំបូងដើម្បីកំណត់ថាតើជនសង្ស័យចង់បានមេធាវីដែរឬអត់ ហើយប្រសិនបើជនសង្ស័យចង់បានមេធាវី នោះត្រូវបង្ហាញបញ្ជីឈ្មោះមេធាវី[62] និងការវាយតម្លៃពីភាពក្រីក្ររបស់ពួកគេ។

៦០. តាមរយៈមុខងាររបស់គាត់ជាអ្នករដ្ឋបាលទទួលបន្ទុកចាត់ចែងធនធានដែលផ្តល់ឱ្យតាមរយៈមូលនិធិទំនុកចិត្តរបស់អង្គការសហប្រជាជាតិ[63] (United Nations Trust Fund) និងកាតព្វកិច្ចរបស់គាត់ស្របតាមវិធាន ៩(៣) នៃវិធានផ្ទៃ ដើម្បីគាំទ្រមន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីក្នុងការបំពេញមុខងារស្វយ័តរបស់នាងដោយផ្តល់សម្ភារៈ អគារ បច្ចេកវិទ្យាព័ត៌មានវិទ្យា ពស្តុភារ យានជំនិះ មធ្យោបាយធ្វើដំណើរ និងសេចក្តីត្រូវការផ្នែករូបវន្ត និងរដ្ឋបាល" អនុប្រធានការិយាល័យរដ្ឋបាលមានកាតព្វកិច្ចទទួលយក និងសម្រួលដល់សំណើរបស់មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីសុំការគាំទ្រផ្នែកសម្ភារៈ និងរដ្ឋបាលដែលចាំបាច់ដើម្បីបំពេញមុខងារស្វយ័តក្នុងអាណត្តិរបស់នាង ។

៦១. ការបដិសេធមកទល់ពេលនេះរបស់អនុប្រធានការិយាល័យរដ្ឋបាលមិនព្រមទទួលយកសំណើរបស់មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីសុំការគាំទ្រផ្នែកសម្ភារៈ និងរដ្ឋបាលដើម្បីធានាឱ្យបាន

---

[61] សូមមើលវិធាន១១ (៦) នៃវិធានផ្ទៃក្នុង។

[62] សូមមើលវិធាន១១ (២) នៃវិធានផ្ទៃក្នុង។

[63] សូមមើលមាត្រា៣១ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក។

00723695



នូវសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានតំណាងផ្នែកច្បាប់ជូនជនសង្ស័យក្នុងសំណុំរឿង 00៣ នាំឲ្យមានការរំលោភដល់សិទ្ធិរបស់ជនសង្ស័យដែលមានចែងក្នុងវិធាន ២១(១) និងវិធាន ២២(១)(ខ) នៃវិធានផ្ទៃក្នុង ។

**៣.៤ អង្គភាពគាំពារការការពារក្ដី ត្រូវការជំនួយជាបន្ទាន់ពីការិយាល័យរដ្ឋបាលដើម្បីទំនាក់ទំនងជនសង្ស័យដើម្បីកំណត់ថា តើពួកគេចង់បានមេធាវីដែរ ឬទេ និងដើម្បីបង្ហាញដល់ពួកគេនូវបញ្ជីឈ្មោះមេធាវី អនុលោមតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុង។**

៦២. [redacted] អាចមិនបានដឹងអំពីប្រការដែលថាពួកគាត់មានសិទ្ធិទទួលបានមេធាវីការពារក្ដីដោយផ្ដល់ថវិកាដោយតុលាការក្នុងករណីដែលពួកគាត់គ្មានមធ្យោបាយបង់ប្រាក់សម្រាប់មេធាវីការពារក្ដីរបស់ពួកគាត់ទេនោះ។ វាជាសិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានព័ត៌មានអំពីសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ។

៦៣. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី មិនមានព័ត៌មានពិស្ដារដែលខ្លួនត្រូវការដើម្បីជូនដំណឹងដល់ជនសង្ស័យអំពីសិទ្ធិរបស់ពួកគេឡើយ ។ ជាងនេះទៅទៀត ដោយសារតែក្ដីបារម្ភផ្នែកសន្តិសុខដោយផ្អែកលើបរិបទនយោបាយទាក់ទងនឹងដំណើរការនីតិវិធីទាំងនេះ[64] ក៏ដូចជាមធ្យោបាយធ្វើដំណើរ និងតម្រូវការផ្នែកសម្ភារៈដទៃទៀតដែលពាក់ព័ន្ធនឹងការបំពេញមុខងាររបស់នាងស្របតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុង មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី ត្រូវការជំនួយជាបន្ទាន់ពីការិយាល័យរដ្ឋបាល ដើម្បីទំនាក់ទំនងជនសង្ស័យ ជូនដំណឹងដល់ពួកគេអំពីសិទ្ធិរបស់ពួកគេ និងបង្ហាញពួកគេនូវបញ្ជីឈ្មោះមេធាវីការពារក្ដី ។

**៣.៥ នៅដំណាក់កាលបណ្ដោះអាសន្ននេះ អនុប្រធានការិយាល័យរដ្ឋបាលត្រូវតែបន្តកិច្ចសន្យាការងារជូន[redacted]**

៦៤. នីតិវិធីទៀងទាត់សម្រាប់ការចាត់តាំងមេធាវីដែលមានចែងក្នុងកថាខណ្ឌ ៦.២ នៃបទបញ្ជារដ្ឋបាល

---

[64] [redacted]

របស់អង្គភាពគាំពារការការពារក្តី[65] ("បទបញ្ជារដ្ឋបាលអង្គភាពគាំពារការការពារក្តី") តម្រូវឱ្យអង្គភាពនេះទំនាក់ទំនងទៅជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទដែលមានសិទ្ធិទទួលបានការតំណាង ដើម្បីវាយតម្លៃពីមធ្យោបាយហិរញ្ញវត្ថុរបស់ពួកគេ បង្ហាញពួកគេនូវបញ្ជីឈ្មោះមេធាវីជាតិ និងមេធាវីអន្តរជាតិ និងផ្តល់ឱ្យពួកគេនូវ "ទម្រង់សំណើសុំការចាត់តាំងមេធាវី" ដែលត្រូវអនុម័តដោយអង្គភាពគាំពារការការពារក្តី និងបញ្ជូនបន្តជាការជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប ។

៦៥. ក្នុងករណីមានការពន្យារដំណើរការដែលមានចែងនៅ កថាខណ្ឌ ៦.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី កថាខណ្ឌ ៦.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពនេះ បានចែងពីការចាត់តាំងជាបណ្តោះអាសន្នមេធាវីការពារក្តីដល់ចុងចោទដែលត្រូវការតំណាងរហូតទល់តែសហមេធាវីត្រូវបានចាត់តាំងជាអចិន្ត្រៃយ៍[66]។

៦៦. យន្តការណ៍នេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានដើម្បីជ្រើសរើស[redacted] ហើយបានឆ្លុះបញ្ចាំងពីច្បាប់ និងការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[67]។ អនុលោមតាមមាត្រា៣៣ថ្មី នៃច្បាប់បង្កើត អវតក នីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ អាចត្រូវលើកយកមកធ្វើជាសំអាងក្នុងករណីដែលមានចន្លោះប្រហោងក្នុងនីតិវិធីដែលមានស្រាប់ ឬក្នុងករណីដែលមានមន្ទិលសង្ស័យកើតឡើងទាក់ទងនឹងការបកស្រាយ ឬភាពស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ។

៦៧. តបតាមសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានតំណាងផ្នែកច្បាប់ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដទៃទៀតដែលមានចែងក្នុងច្បាប់បង្កើត អវតក វិធានផ្ទៃក្នុង និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កិច្ចសន្យារបស់[redacted] ត្រូវតែបន្តដើម្បីផ្តល់លទ្ធភាពឱ្យអង្គភាពគាំពារការការពារក្តី អាចធានាបាននូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយ

---

[65] អនុម័ត កាលពីខែកក្កដា ឆ្នាំ២០០៧, អនុលោមតាមវិធាន១១(២) (ក) (ii) នៃវិធានផ្ទៃក្នុង។

[66] កថាខណ្ឌ៦.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី "ប្រសិនបើមានការពន្យាក្នុងដំណើរការចាត់តាំងមេធាវី ហើយជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ត្រូវការការពារក្តី អង្គភាពគាំពារការការពារក្តីអាចចាត់តាំងមេធាវីបណ្តោះអាសន្នម្នាក់ ឬលើសពីមួយនាក់ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះមេធាវី រហូតទល់តែមានការចាត់តាំងមេធាវីជាអចិន្ត្រៃយ៍"។

[67] សូមមើលឧទាហរណ៍មាត្រា៥៦(២) (គ) នៃលក្ខន្តិកៈទីក្រុងរ៉ូម និងបទបញ្ជា៧៦នៃបទបញ្ជារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

យុត្តិធម៌របស់ជនសង្ស័យដែលរង់ចាំការចាត់តាំងមេធាវីការពារក្តីដល់ពួកគេ អនុលោមតាមវិធាន ២២ (១) (ខ) នៃវិធានផ្ទៃក្នុង។

**៣.៦ ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវតែផ្អាកដើម្បីចាត់វិធានការចាំបាច់ទាំងអស់ដើម្បីរក្សាឲ្យបាននូវសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានតំណាងផ្នែកច្បាប់**

៦៨. ដំណើរការនីតិវិធីផ្សេងៗនៅចំពោះមុខអង្គបុរេជំនុំជម្រះដែលមានចែងក្នុងផ្នែក ២.២ នៃញត្តិនេះ តម្រូវឲ្យមានការចូលរួមពីមេធាវីការពារក្តី ព្រោះជនសង្ស័យមានសិទ្ធិទទួលបានសិទ្ធិជាមូលដ្ឋាន ទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាព។

៦៩. ការបន្តដំណើរការនីតិវិធីទាំងនេះដោយគ្មានការចូលរួមពីមេធាវីការពារក្តី នឹងរំលោភបំពានលើផ្នែកជាច្រើននៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយតតាំងក្តី សិទ្ធិទទួលបានការតំណាងប្រកបដោយប្រសិទ្ធិភាព និងសិទ្ធិទទួលបានការគោរពគោលការណ៍ចំពោះមុខដែលមានចែងក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង។

៧០. ដូច្នេះ ដំណើរការនីតិវិធី ត្រូវតែផ្អាកដើម្បីឲ្យអង្គភាពគាំពារការការពារក្តី ដោយមានការគាំទ្រពីការិយាល័យរដ្ឋបាល និងអង្គភាពពាក់ព័ន្ធទាំងអស់ ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីធានាសិទ្ធិជាមូលដ្ឋានរបស់ជនងសង្ស័យទទួលបានការតំណាងផ្នែកច្បាប់ សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងបញ្ហាដទៃទៀតដែលអង្គបុរេជំនុំជម្រះចាត់ទុកថាសមស្រប ។

## V. ដំណោះស្រាយ

៧១. អាស្រ័យលើមូលហេតុដូចដែលបានគូសបញ្ជាក់ពីខាងលើ:

ក. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី សូមស្នើឲ្យអង្គបុរេជំនុំជម្រះផ្អាកដំណើរការនីតិវិធី នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដើម្បីឲ្យអង្គភាពនេះ ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីផ្តល់ការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពដល់ជនសង្ស័យក្នុងសំណុំរឿង ០០៣ សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងបញ្ហាដទៃទៀតដែលអង្គបុរេជំនុំជម្រះចាត់ទុកថាសមស្រប ។

ខ. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី សូមស្នើឲ្យអង្គបុរេជំនុំជម្រះបង្គាប់ឲ្យការិយាល័យរដ្ឋបាលផ្តល់ជំនួយផ្នែកសម្ភារៈ ហិរញ្ញវត្ថុ និងរដ្ឋបាលដល់អង្គភាពគាំពារការការ

ពារក្តីដែលត្រូវការជាចាំបាច់ដើម្បីទំនាក់ទំនងជនសង្ស័យ និងបង្ហាញពួកគេនូវបញ្ជីឈ្មោះមេធាវីការពារក្តី ដូចដែលមានចែងក្នុងវិធាន ១១ (២) (ង) នៃវិធានផ្ទៃក្នុង សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងបញ្ហាដទៃទៀតដែលអង្គបុរេជំនុំជម្រះចាត់ទុកថាសមស្រប ។

គ. ក្នុងរយៈពេលបណ្តោះអាសន្ននេះ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី សូមស្នើឱ្យអង្គបុរេជំនុំជម្រះចេញដីកាបង្គាប់ដល់អនុប្រធានការិយាល័យរដ្ឋបាលដោយបង្ខំឱ្យគាត់បន្តកិច្ចសន្យាការងារដល់[redacted]និង

ឃ. អនុលោមតាមកម្មវត្ថុនៃតម្លាភាព និងការយល់ដឹងរបស់សាធារណជនអំពីដំណើរការយុត្តិធម៌ អង្គភាពគាំពារការការពារក្តីសូមស្នើឱ្យចាត់ចំណាត់ថ្នាក់ញាតិនេះជាឯកសារ "សាធារណៈ" នៅពេលការកោសលុបចាំបាច់ត្រូវបានធ្វើឡើង ។

សូមលោក/លោកស្រីចៅក្រមអង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះដោយក្តីគោរព។

Nisha Valabhji

**មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី**

**ធ្វើនៅភ្នំពេញថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១**